**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ១៩ អនក្រ.បក**

ក្រសួងបរិស្ថាន
ចូល
លេខ: 1321
ថ្ងៃទី 22 ខែ 02 ឆ្នាំ2021
ម៉ោង 05:00

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា៧ មាត្រា១២ មាត្រា១៣ មាត្រា១៤ ឧបសម្ព័ន្ធ២ ឧបសម្ព័ន្ធ៣ និងឧបសម្ព័ន្ធ៤ នៃអនុក្រឹត្យលេខ១៨០ អនក្រ.បក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងលើការចាត់ថ្នាក់និងការដាក់ស្លាកសញ្ញាសារធាតុគីមី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៦/០២ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងឱសថ

- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៥/០០៥ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីអាវុធគីមី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៦ ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះនិងគ្រាប់រំសេវ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រនិងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្តង់ដារកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១១ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា៦ មាត្រា៧ មាត្រា៨ មាត្រា៩ មាត្រា១១ មាត្រា១២ ចំណងជើងជំពូកទី៤ មាត្រា១៦ មាត្រា១៩ មាត្រា២៦ មាត្រា៥០ មាត្រា៥១ មាត្រា៥២ មាត្រា៥៣ មាត្រា៥៤ មាត្រា៥៥ មាត្រា៥៦ មាត្រា៥៧ មាត្រា៥៨ មាត្រា៥៩ មាត្រា៦៥ មាត្រា៦៦ មាត្រា៦៧ និងមាត្រា៦៨ នៃច្បាប់ស្តីពីស្តង់ដារកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៧៥ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៦៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៨ ស្តីពីបមាណីយនិងការគ្រប់គ្រងសំភារៈកសិកម្ម
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ២៨ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
- បានឃើញអនុក្រឹត្យលេខ១៨០ អនក្រ.បក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ ស្ដីពីការគ្រប់គ្រងលើការចាត់ថ្នាក់និងការដាក់ស្លាកសញ្ញាសារធាតុគីមី
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.កប ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រាមួយ .-**

មាត្រា៧ មាត្រា១២ មាត្រា១៣ មាត្រា១៤ ឧបសម្ព័ន្ធ២ ឧបសម្ព័ន្ធ៣ និងឧបសម្ព័ន្ធ៤ នៃអនុក្រឹត្យលេខ១៨០ អនក្រ.បក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ ស្ដីពីការគ្រប់គ្រងលើការចាត់ថ្នាក់និងការដាក់ស្លាកសញ្ញាសារធាតុគីមី ត្រូវបានកែសម្រួលដូចតទៅ៖

**មាត្រា៧ .- ថ្មី**

ការចាត់ថ្នាក់ភាពបង្កគ្រោះថ្នាក់ ការដាក់រូបសញ្ញានៃភាពអាចបង្កគ្រោះថ្នាក់ និងទម្រង់គោលនៃឯកសារព័ត៌មានអំពីសុវត្ថិភាពសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ត្រូវអនុលោមទៅតាមឯកសារបទដ្ឋានបច្ចេកទេសស្ដីពីប្រព័ន្ធស៊ីចង្វាក់ជាសកលអំពីការចាត់ថ្នាក់និងការដាក់ស្លាកសញ្ញាសារធាតុគីមី ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ២ នៃអនុក្រឹត្យនេះ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងបរិស្ថានអាចចេញប្រកាសលើការកែសម្រួលឬបំពេញបន្ថែមនូវឧបសម្ព័ន្ធ២ នៃអនុក្រឹត្យនេះ ដោយមានកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

**មាត្រា១២ .- ថ្មី**

ព័ត៌មានអំពីភាពអាចបង្កគ្រោះថ្នាក់ដែលតម្រូវឱ្យមាននៅលើស្លាកសញ្ញាសារធាតុគីមីដែលត្រូវបិទនៅលើសម្ភារៈវេចខ្ចប់សារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ត្រូវរៀបចំតាមលំដាប់រៀងនៃប្រភេទនិងកម្រិតនៃភាពបង្កគ្រោះថ្នាក់របស់សារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ២ នៃអនុក្រឹត្យនេះ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងបរិស្ថានអាចចេញប្រកាសលើការកែសម្រួលឬបំពេញបន្ថែមនូវឧបសម្ព័ន្ធ២ នៃអនុក្រឹត្យនេះ ដោយមានកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

**មាត្រា១៣ ._ ថ្មី**

ទម្រង់និងពណ៌របស់រូបសញ្ញានៃភាពអាចគ្រោះថ្នាក់ដែលតម្រូវឱ្យមាននៅលើស្លាកសញ្ញាសារធាតុគីមីដែលត្រូវបិទនៅលើសម្ភារៈវេចខ្ចប់នៃសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ ត្រូវអនុលោមតាមការកំណត់នៃឯកសារបទដ្ឋានបច្ចេកទេសស្តីពីប្រព័ន្ធស៊ីចង្វាក់ជាសកលអំពីការចាត់ថ្នាក់និងការដាក់ស្លាកសញ្ញាសារធាតុគីមី ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ៣ នៃអនុក្រឹត្យនេះ។

ដោយឡែក ទំហំនៃរូបសញ្ញាភាពអាចបង្កគ្រោះថ្នាក់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងបរិស្ថានអាចចេញប្រកាសលើការកែសម្រួលឬបំពេញបន្ថែមនូវឧបសម្ព័ន្ធ៣ នៃអនុក្រឹត្យនេះ ដោយមានកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

**មាត្រា១៤ ._ ថ្មី**

សារធាតុគីមីនិងផលិតផលគីមីដែលត្រូវបានចរាចរនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវតែមានភ្ជាប់ជាមួយនូវឯកសារព័ត៌មានអំពីសុវត្ថិភាព ដោយអនុលោមតាមប្រកាស និងសារាចរណែនាំរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងអនុលោមតាមឯកសារបទដ្ឋានបច្ចេកទេសស្តីពីប្រព័ន្ធចង្វាក់ជាសកលអំពីការចាត់ថ្នាក់និងការដាក់ស្លាកសញ្ញាសារធាតុគីមី។ ទម្រង់គោលនៃឯកសារព័ត៌មានអំពីសុវត្ថិភាពសម្រាប់សារធាតុគីមីនិងផលិតផលគីមីមានកំណត់ក្នុងឧបសម្ព័ន្ធ៤ នៃអនុក្រឹត្យនេះ។

អក្សរដែលសរសេរក្នុងឯកសារព័ត៌មានអំពីសុវត្ថិភាព ដូចមានចែងក្នុងកថាខណ្ឌខាងលើ ត្រូវអនុវត្តដូចខាងក្រោម៖

ក. សម្រាប់សារធាតុគីមីនិងផលិតផលគីមីដែលបាននាំចូលពីបរទេសត្រូវមានឯកសារព័ត៌មានអំពីសុវត្ថិភាពបន្ថែមជាភាសាខ្មែរ មុនពេលចែកចាយ ឬមុនយកទៅប្រើប្រាស់។

ខ. សម្រាប់សារធាតុគីមីនិងផលិតផលគីមីដែលធ្វើការផលិតឬវេចខ្ចប់ឡើងវិញនៅក្នុងស្រុកត្រូវមានឯកសារព័ត៌មានអំពីសុវត្ថិភាពជាភាសាខ្មែរ មុនពេលដឹកចេញពីទីតាំងផលិតឬវេចខ្ចប់ឡើងវិញ។

គ. ចំពោះចំណុចដែលមានលក្ខណៈទូទៅពាក់ព័ន្ធនឹងសារធាតុគីមីនិងផលិតផលគីមី ដូចជាឈ្មោះពាណិជ្ជកម្ម ឈ្មោះគីមីទូទៅ អាចអនុញ្ញាតឱ្យប្រើជាភាសាអង់គ្លេសឬបារាំង នៅក្នុងឯកសារព័ត៌មានអំពីសុវត្ថិភាពដែលមានចែងក្នុងចំណុច**ក** និង**ខ** នៃមាត្រានេះ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងបរិស្ថានអាចចេញប្រកាសលើការកែសម្រួលឬបំពេញបន្ថែមនូវឧបសម្ព័ន្ធ៤ នៃអនុក្រឹត្យនេះ ដោយមានកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

**មាត្រាពីរ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៣ ១៣ ១៣ ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ២ នៃអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០២១
# ស្តីពី
# ការកែសម្រួលមាត្រា៧ មាត្រា១២ មាត្រា១៣ មាត្រា១៤ ឧបសម្ព័ន្ធ២ ឧបសម្ព័ន្ធ៣ និងឧបសម្ព័ន្ធ៤ នៃអនុក្រឹត្យលេខ១៨០ អនក្រ.បក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងលើការចាត់ថ្នាក់និងការដាក់ស្លាកសញ្ញាសារធាតុគីមី

## ១. ក្រុមសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ដែលអាចបង្កគ្រោះថ្នាក់ជាលក្ខណៈរូប

### ១.១. សារធាតុផ្ទុះ

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | លេខកូដបង្កគ្រោះថ្នាក់ |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្កគ្រោះថ្នាក់ | ក្រុមបង្កគ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្កគ្រោះថ្នាក់ GHS | រូបសញ្ញានៃភាពបង្កគ្រោះថ្នាក់ UN Model Regulations | ពាក្យព្រមាន | ភាពអាចបង្កគ្រោះថ្នាក់ | |
| សារធាតុផ្ទុះ | សារធាតុផ្ទុះដែលមិនលំនឹង |  | ការមិនអនុញ្ញាតឱ្យដឹកជញ្ជូន | សញ្ញាបង្កគ្រោះថ្នាក់ | ងាយនឹងផ្ទុះ | H200 |
| | ចំណាត់ថ្នាក់ ១.១. |  |  | | ងាយនឹងផ្ទុះ<br>បង្កគ្រោះថ្នាក់ទ្រង់ទ្រាយធំ | H201 |
| | ចំណាត់ថ្នាក់ ១.២. |  |  | | ងាយនឹងផ្ទុះ<br>បង្កគ្រោះថ្នាក់ធ្ងន់ធ្ងរ | H202 |
| | ចំណាត់ថ្នាក់ ១.៣. |  |  | | ងាយនឹងផ្ទុះ<br>បង្កគ្រោះថ្នាក់ដោយ ភ្លើង ការផ្ទុះ ឬ គ្រោះថ្នាក់ទ្រង់ទ្រាយតូច | H203 |

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | លេខកូដបង្គ្រោះថ្នាក់ |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គ្រោះថ្នាក់ | ក្រុមបង្គ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ GHS | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ UN Model Regulations | ពាក្យព្រមាន | ភាពអាចបង្គ្រោះថ្នាក់ | |
| | ការបែងចែក ១.៤. |  |  | សញ្ញាព្រមាន | អគ្គីភ័យឬបង្កនូវហានិភ័យ | H204 |
| | ការបែងចែក ១.៥. | គ្មានរូបសញ្ញា |  | សញ្ញាបង្គ្រោះថ្នាក់ | អាចនឹងផ្ទុះកដោយភ្លើងឆេះ | H205 |
| | ការបែងចែក ១.៦. | គ្មានរូបសញ្ញា |  | គ្មានសញ្ញាបង្គ្រោះថ្នាក់ | គ្មានភាពបង្គ្រោះថ្នាក់ | គ្មាន |

## ១.២. ឧស្ម័នងាយឆាបឆេះ

| ការចាត់ថ្នាក់ | | | ការដាក់ស្លាកសញ្ញា | | | | លេខកូដបង្គ្រោះថ្នាក់ |
|---|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គ្រោះថ្នាក់ | ក្រុមបង្គ្រោះថ្នាក់ | | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ GHS | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ UN Model Regulations | ពាក្យព្រមាន | ភាពអាចបង្គ្រោះថ្នាក់ | |
| ឧស្ម័នងាយឆាបឆេះ | 1A | ឧស្ម័នដែលងាយឆាបឆេះ |  |  | សញ្ញាបង្គ្រោះថ្នាក់ | ឧស្ម័នងាយឆាបឆេះខ្លាំង | H220 |
| | | Pyrophoric gas |  |  | សញ្ញាបង្គ្រោះថ្នាក់ | ឧស្ម័នងាយឆាបឆេះខ្លាំង | H220 |

| ការចាត់ថ្នាក់ | | | ការដាក់ស្លាកសញ្ញា | | | | លេខកូដបង្គ្រោះថ្នាក់ |
|---|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គ្រោះថ្នាក់ | ក្រុមបង្គ្រោះថ្នាក់ | | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ | | ពាក្យព្រមាន | ភាពអាចបង្គ្រោះថ្នាក់ | |
| | | | GHS | UN Model Regulations | | | |
| | ឧស្ម័នដែលគ្មានលំនឹងគីមី | A |  |   | សញ្ញាបង្គ្រោះថ្នាក់ | ឧស្ម័នងាយឆាបឆេះខ្លាំង | H220 H230 |
| | | B |  |   | សញ្ញាបង្គ្រោះថ្នាក់ | ឧស្ម័នងាយឆាបឆេះខ្លាំង នៅពេលគ្មានខ្យល់ | H220 H230 |
| | 1B | |  |   | សញ្ញាបង្គ្រោះថ្នាក់ | ឧស្ម័នងាយឆាបឆេះ | H221 |
| | 2 | | គ្មានរូបសញ្ញា | មិនចាំបាច់ | សញ្ញាព្រមាន | ឧស្ម័នឆាបឆេះ | H221 |

១.៣. ចំហាយងាយឆាបឆេះ

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | លេខកូដបង្គ្រោះថ្នាក់ |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គ្រោះថ្នាក់ | ក្រុមបង្គ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ | | ពាក្យព្រមាន | ភាពអាចបង្គ្រោះថ្នាក់ | |
| | | GHS | UN Model Regulations | | | |
| ចំហាយងាយឆាបឆេះ | 1 |  |   | សញ្ញាបង្គ្រោះថ្នាក់ | សារធាតុងាយឆាបឆេះខ្លាំង កំប៉ុងសម្ពាធអាចផ្ទុះ ប្រសិនបើត្រូវកម្ដៅ | H222 H229 |

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | លេខកូដបង្គ្រោះថ្នាក់ |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គ្រោះថ្នាក់ | ក្រុមបង្គ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ GHS | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ UN Model Regulations | ពាក្យព្រមាន | ភាពអាចបង្គ្រោះថ្នាក់ | |
| | 2 |  |  | សញ្ញាព្រមាន | សារធាតុងាយឆាបឆេះ<br>កំប៉ុងសម្ពាធអាចផ្ទុះ<br>ប្រសិនត្រូវកម្តៅ | H223<br>H229 |
| | 3 | គ្មានរូបសញ្ញា |  | សញ្ញាព្រមាន | ធុងសម្ពាធអាចផ្ទុះ<br>ប្រសិនត្រូវកម្តៅ | H229 |

## ១.៤. ឧស្ម័នឆេះផ្ទុះ

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | លេខកូដបង្គ្រោះថ្នាក់ |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គ្រោះថ្នាក់ | ក្រុមបង្គ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ GHS | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ UN Model Regulations | ពាក្យព្រមាន | ភាពអាចបង្គ្រោះថ្នាក់ | |
| ឧស្ម័នឆេះផ្ទុះ | 1 |  |  | សញ្ញាបង្គ្រោះថ្នាក់ | អាចបង្កឱ្យមានអគ្គិភ័យ<br>អុកស៊ីតកម្ម | H270 |

## ១.៥. ឧស្ម័នក្រោមសម្ពាធខ្ពស់

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គគ្រោះថ្នាក់ | ក្រុមបង្គគ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្គគ្រោះថ្នាក់ GHS | រូបសញ្ញានៃភាពបង្គគ្រោះថ្នាក់ UN Model Regulations | ពាក្យព្រមាន | ភាពអាចបង្គគ្រោះថ្នាក់ | លេខកូដបង្គគ្រោះថ្នាក់ |
| ឧស្ម័នក្រោមសម្ពាធខ្ពស់ | ឧស្ម័នបង្ហាប់ |  |  | សញ្ញាព្រមាន | ផ្ទុកឧស្ម័នរងសម្ពាធ អាចផ្ទុះប្រសិនត្រូវកម្ដៅ(ភ្លើង) | H280 |
| | ឧស្ម័នរាវ |  |  | សញ្ញាព្រមាន | ផ្ទុកឧស្ម័នរងសម្ពាធ អាចផ្ទុះប្រសិនត្រូវកម្ដៅ(ភ្លើង) | H280 |
| | ឧស្ម័នរាវត្រជាក់ |  |  | សញ្ញាព្រមាន | ផ្ទុកឧស្ម័នរងសម្ពាធ, អាចផ្ទុះប្រសិនត្រូវកម្ដៅ(ភ្លើង) | H281 |
| | ឧស្ម័នរំលាយ |  |  | សញ្ញាព្រមាន | ផ្ទុកឧស្ម័នរងសម្ពាធ មានសីតុណ្ហភាពទាបអាចបណ្តាល ឱ្យរលាកឬរបួស | H280 |

### ១.៦. សារធាតុរាវងាយឆាបឆេះ

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | លេខកូដបង្គ្រោះថ្នាក់ |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គ្រោះថ្នាក់ | ក្រុមបង្គ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ GHS | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ UN Model Regulations | ពាក្យព្រមាន | ភាពអាចបង្គ្រោះថ្នាក់ | |
| សារធាតុរាវងាយឆាបឆេះ | 1 |  |  | សញ្ញាបង្គ្រោះថ្នាក់ | អង្គធាតុរាវនិងចំហាយងាយឆាបឆេះខ្លាំងបំផុត ( Extremely ) | H224 |
| | 2 |  |  | សញ្ញាបង្គ្រោះថ្នាក់ | អង្គធាតុរាវនិងចំហាយងាយឆាបឆេះខ្លាំង ( Highly ) | H225 |
| | 3 |  |  | សញ្ញាបង្គ្រោះថ្នាក់ | អង្គធាតុរាវនិងចំហាយងាយឆាបឆេះ | H226 |
| | 4 | គ្មានរូបសញ្ញា | មិនត្រូវការ | សញ្ញាបង្គ្រោះថ្នាក់ | អង្គធាតុងាយឆាបឆេះ | H227 |

### ១.៧. សារធាតុរឹងងាយឆាបឆេះ

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | លេខកូដបង្គ្រោះថ្នាក់ |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គ្រោះថ្នាក់ | ក្រុមបង្គ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ GHS | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ UN Model Regulations | ពាក្យព្រមាន | ភាពអាចបង្គ្រោះថ្នាក់ | |
| សារធាតុរឹងងាយឆាបឆេះ | 1 |  |  | សញ្ញាបង្គ្រោះថ្នាក់ | ភាពរូបរឹងងាយឆាបឆេះ | H228 |

| | | | | | | |
|---|---|---|---|---|---|---|
| | 2 |  |  | សញ្ញាព្រមាន | ភាពរូបរឹងងាយឆាបឆេះ | H228 |

## ១.៨_ សារធាតុងាយមានប្រតិកម្មដោយខ្លួនឯង

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | លេខកូដបង្គ្រោះថ្នាក់ |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គ្រោះថ្នាក់ | ក្រុមបង្គ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ | | ពាក្យព្រមាន | ភាពអាចបង្គ្រោះថ្នាក់ | |
| | | GHS | UN Model Regulations | | | |
| សារធាតុងាយមានប្រតិកម្មដោយខ្លួនឯង | ប្រភេទ A |  | មិនអនុញ្ញាតឱ្យដឹកជញ្ជូន | សញ្ញាបង្គ្រោះថ្នាក់ | ការផ្ទុតកម្តៅអាចបង្កឱ្យឆេះឬផ្ទុះ | H240 |
| | ប្រភេទ B |   |   | សញ្ញាបង្គ្រោះថ្នាក់ | ការផ្ទុតកម្តៅអាចបង្កឱ្យឆេះ | H241 |
| | ប្រភេទCនិងD |  |  | សញ្ញាបង្គ្រោះថ្នាក់ | ការផ្ទុតកម្តៅអាចបង្កឱ្យឆេះ | H242 |
| | ប្រភេទEនិងF |  |  | សញ្ញាព្រមាន | ការផ្ទុតកម្តៅអាចបង្កឱ្យឆេ[illegible] | H24[illegible] |

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គគ្រោះថ្នាក់ | ក្រុមបង្កគ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្កគ្រោះថ្នាក់ | | ពាក្យព្រមាន | ភាពអាចបង្កគ្រោះថ្នាក់ | លេខកូដបង្កគ្រោះថ្នាក់ |
| | | GHS | UN Model Regulations | | | |
| | ប្រភេទG | គ្មានរូបសញ្ញា | មិនត្រូវការ | គ្មានសញ្ញា | គ្មានកម្រិតគ្រោះថ្នាក់ | គ្មាន |

## ១.៩. សារធាតុរាវដែលអាចឆេះក្រោយពេលប៉ះនឹងខ្យល់៥នាទី

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្កគ្រោះថ្នាក់ | ក្រុមបង្កគ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្កគ្រោះថ្នាក់ | | ពាក្យព្រមាន | ភាពអាចបង្កគ្រោះថ្នាក់ | លេខកូដបង្កគ្រោះថ្នាក់ |
| | | GHS | UN Model Regulations | | | |
| សារធាតុរាវដែលអាចឆេះក្រោយពេលប៉ះនឹងខ្យល់៥នាទី | 1 |  |  | សញ្ញាបង្កគ្រោះថ្នាក់ | បង្កជាអគ្គីភ័យឆាបឆេះប្រសិនប៉ះខ្យល់ | H250 |

## ១.១០. សារធាតុរឹងដែលអាចឆេះក្រោយពេលប៉ះនឹងខ្យល់៥នាទី

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្កគ្រោះថ្នាក់ | ក្រុមបង្កគ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្កគ្រោះថ្នាក់ | | ពាក្យព្រមាន | ភាពអាចបង្កគ្រោះថ្នាក់ | លេខកូដបង្កគ្រោះថ្នាក់ |
| | | GHS | UN Model Regulations | | | |
| សារធាតុរឹងដែលអាចឆេះក្រោយពេលប៉ះនឹងខ្យល់៥នាទី | 1 |  |  | សញ្ញាបង្កគ្រោះថ្នាក់ | បង្កជាអគ្គីភ័យឆាបឆេះប្រសិនប៉ះជាមួយខ្យល់ | H250 |

## ១.១១. សារធាតុ និងល្បាយដែលឆេះដោយខ្លួនឯង

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គ្រោះថ្នាក់ | ក្រុមបង្គ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ | | ពាក្យព្រមាន | ភាពអាចបង្គ្រោះថ្នាក់ | លេខកូដបង្គ្រោះថ្នាក់ |
| | | GHS | UN Model Regulations | | | |
| សារធាតុនិងល្បាយដែលឆេះដោយខ្លួនឯង | 1 |  |  | សញ្ញាបង្គ្រោះថ្នាក់ | កម្តៅកើតឡើងដោយខ្លួនឯង អាចបង្កឱ្យឆេះ | H251 |
| | 2 |  |  | សញ្ញាព្រមាន | កម្តៅកើតឡើងដោយខ្លួនឯង ក្នុងបរិមាណច្រើន អាចបង្កឱ្យឆេះ | H252 |

## ១.១២. សារធាតុនិងល្បាយដែលប៉ះនឹងទឹក ប្លែងទៅជាឧស្ម័នឆាបឆេះ

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គ្រោះថ្នាក់ | ក្រុមបង្គ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ | | ពាក្យព្រមាន | ភាពអាចបង្គ្រោះថ្នាក់ | លេខកូដបង្គ្រោះថ្នាក់ |
| | | GHS | UN Model Regulations | | | |
| សារធាតុ និងល្បាយដែលប៉ះនឹងទឹកប្លែងទៅជាឧស្ម័នឆាបឆេះ | 1 |  |  | សញ្ញាបង្គ្រោះថ្នាក់ | ពេលប៉ះនឹងទឹកបញ្ចេញនូវឧស្ម័នងាយឆាបឆេះដែលអាចនឹងឆាបឆេះ | H260 |
| | 2 |  |  | សញ្ញាបង្គ្រោះថ្នាក់ | ពេលប៉ះនឹងទឹកបញ្ចេញនូវឧស្ម័នឆាបឆេះអាចបង្កឱ្យឆាបឆេះ | H261 |

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | លេខកូដបង្គ្រោះថ្នាក់ |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គ្រោះថ្នាក់ | ក្រុមបង្គ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ GHS | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ UN Model Regulations | ពាក្យព្រមាន | ភាពអាចបង្គ្រោះថ្នាក់ | |
| | 3 |  |  | សញ្ញាព្រមាន | ពេលប៉ះនឹងទឹកបញ្ចេញនូវបែឧស្ម័នងាយឆាបឆេះ | H261 |

## ១.១៣. សារធាតុភាវឆេះផ្ទុះ

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | លេខកូដបង្គ្រោះថ្នាក់ |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គ្រោះថ្នាក់ | ក្រុមបង្គ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ GHS | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ UN Model Regulations | ពាក្យព្រមាន | ភាពអាចបង្គ្រោះថ្នាក់ | |
| សារធាតុភាវឆេះផ្ទុះ | 1 |  |  | សញ្ញាបង្គ្រោះថ្នាក់ | អាចបង្កឱ្យឆេះ ឬផ្ទុះ អុកស៊ីតកម្មខ្លាំង | H271 |
| | 2 |  |  | សញ្ញាបង្គ្រោះថ្នាក់ | អាចនឹងបង្កឱ្យឆេះកាន់តែខ្លាំង អុកស៊ីតកម្ម | H272 |
| | 3 |  |  | សញ្ញាព្រមាន | អាចនឹងបង្កឱ្យឆេះកាន់តែខ្លាំង អុកស៊ីតកម្ម | H272 |

## ១.១៤. សារធាតុរឹងឆេះផ្ទុះ

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | លេខកូដបង្គ្រោះថ្នាក់ |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គ្រោះថ្នាក់ | ក្រុមបង្គ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ GHS | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ UN Model Regulations | ពាក្យព្រមាន | ភាពអាចបង្គ្រោះថ្នាក់ | |
| សារធាតុរឹងឆេះផ្ទុះ | 1 |  |  | សញ្ញាបង្គ្រោះថ្នាក់ | អាចបង្កឱ្យឆេះឬផ្ទុះ អុកស៊ីតកម្មខ្លាំង | H271 |
| | 2 |  |  | សញ្ញាបង្គ្រោះថ្នាក់ | អាចនឹងបង្កឱ្យឆេះកាន់តែខ្លាំង អុកស៊ីតកម្ម | H272 |
| | 3 |  |  | សញ្ញាព្រមាន | អាចនឹងបង្កឱ្យឆេះកាន់តែខ្លាំង អុកស៊ីតកម្ម | H272 |

## ១.១៥. សារធាតុពែអុកស៊ីតសរីរាង្គ

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | លេខកូដបង្គ្រោះថ្នាក់ |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គ្រោះថ្នាក់ | ក្រុមបង្គ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ GHS | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ UN Model Regulations | ពាក្យព្រមាន | ភាពអាចបង្គ្រោះថ្នាក់ | |
| សារធាតុពែអុកស៊ីតសរីរាង្គ | ប្រភេទA |  | ការដឹកជញ្ជូនមិនត្រូវបានអនុញ្ញាត | សញ្ញាបង្គ្រោះថ្នាក់ | ការដុតកម្តៅអាចបង្កឱ្យផ្ទុះបាន | H240 |

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គ្រោះថ្នាក់ | ក្រុមបង្គ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ GHS | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ UN Model Regulations | ពាក្យព្រមាន | ភាពអាចបង្គ្រោះថ្នាក់ | លេខកូដបង្គ្រោះថ្នាក់ |
| | ប្រភេទB |  |  | សញ្ញាបង្គ្រោះថ្នាក់ | ការដុតកម្តៅអាចបង្កឱ្យឆេះឬផ្ទុះ | H241 |
| | ប្រភេទCនិងD |  |  | សញ្ញាបង្គ្រោះថ្នាក់ | ការដុតកម្តៅអាចបង្កឱ្យឆេះ | H242 |
| | ប្រភេទEនិងF |  |  | សញ្ញាព្រមាន | ការដុតកម្តៅអាចបង្កឱ្យឆេះ | H242 |
| | ប្រភេទG | គ្មានរូបសញ្ញា | មិនត្រូវការ | គ្មានសញ្ញាព្រមាន | គ្មានភាពបង្គ្រោះថ្នាក់ | គ្មាន |

## ១.១៦_ សារធាតុបង្កច្រេះស៊ីលោហៈ

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គ្រោះថ្នាក់ | ក្រុមបង្គ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ GHS | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ UN Model Regulations | ពាក្យព្រមាន | ភាពអាចបង្គ្រោះថ្នាក់ | លេខកូដបង្គ្រោះថ្នាក់ |
| សារធាតុបង្កច្រេះស៊ីលោហៈ | 1 |  |  | សញ្ញាព្រមាន | អាចបង្កឱ្យមានអុកស៊ីតកម្ម ដល់លោហៈ | H290 |

## ១.១៧. សារធាតុផ្ទុះដែលមានលក្ខណៈរួស (Desensitized explosives)

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | លេខកូដបង្គ្រោះថ្នាក់ |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គ្រោះថ្នាក់ | ក្រុមបង្គ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ | | ពាក្យព្រមាន | ភាពអាចបង្គ្រោះថ្នាក់ | |
| | | GHS | UN Model Regulations | | | |
| សារធាតុផ្ទុះដែលមានលក្ខណៈរួស (Desensitized explosives) | 1 |  | មិនមាន | សញ្ញាបង្គ្រោះថ្នាក់ | បង្កអគ្គីភ័យ បន្ទុះ កើនឡើងនូវបន្ទុះ ប្រសិនបើភ្នាក់ងារដែលមានលក្ខណៈរួសត្រូវបានកាត់បន្ថយ | H206 |
| | 2 |  | មិនមាន | សញ្ញាបង្គ្រោះថ្នាក់ | បង្កអគ្គីភ័យ បន្ទុះ កើនឡើងនូវបន្ទុះ ប្រសិនបើភ្នាក់ងារដែលមានលក្ខណៈរួសត្រូវបានកាត់បន្ថយ | H207 |
| | 3 |  | មិនមាន | សញ្ញាព្រមាន | បង្កអគ្គីភ័យ បន្ទុះ កើនឡើងនូវបន្ទុះ ប្រសិនបើភ្នាក់ងារដែលមានលក្ខណៈរួសត្រូវបានកាត់បន្ថយ | H207 |
| | 4 |  | មិនមាន | សញ្ញាព្រមាន | បង្កអគ្គីភ័យ បន្ទុះ កើនឡើងនូវបន្ទុះ ប្រសិនបើភ្នាក់ងារដែលមានលក្ខណៈរួសត្រូវបានកាត់បន្ថយ | H208 |

## ២. ក្រុមសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ដែលអាចបង្កគ្រោះថ្នាក់ផ្ទាល់ដល់សុខភាព

### ២.១. ពុលធ្ងន់ធ្ងរ

| ការចាត់ថ្នាក់ | | | ការដាក់ស្លាកសញ្ញា | | | | |
|---|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្កគ្រោះថ្នាក់ | ក្រុមបង្កគ្រោះថ្នាក់ | | រូបសញ្ញានៃភាពបង្កគ្រោះថ្នាក់ GHS | រូបសញ្ញានៃភាពបង្កគ្រោះថ្នាក់ UN Model Regulations | ពាក្យព្រមាន | ភាពអាចបង្កគ្រោះថ្នាក់ | លេខកូដបង្កគ្រោះថ្នាក់ |
| ពុលធ្ងន់ធ្ងរ | 1 | ផ្ទាល់មាត់ |  |  | សញ្ញាបង្កគ្រោះថ្នាក់ | អាចបណ្តាលឱ្យស្លាប់ប្រសិនបើលេបចូល | H300 |
| | | Dermal | | | | អាចបណ្តាលឱ្យស្លាប់ប្រសិនបើប៉ះជាមួយស្បែក | H310 |
| | | ការដកដង្ហើមចូល | | | | អាចបណ្តាលឱ្យស្លាប់ប្រសិនបើដកដង្ហើមចូល | H330 |
| | 2 | ផ្ទាល់មាត់ |  |  | សញ្ញាបង្កគ្រោះថ្នាក់ | អាចបណ្តាលឱ្យស្លាប់ប្រសិនបើលេបចូល | H300 |
| | | Dermal | | | | អាចបណ្តាលឱ្យស្លាប់ប្រសិនបើប៉ះជាមួយស្បែក | H310 |
| | | ការដកដង្ហើមចូល | | | | អាចបណ្តាលឱ្យស្លាប់ប្រសិនបើដកដង្ហើមចូល | H330 |
| | 3 | ផ្ទាល់មាត់ |  |  | សញ្ញាបង្កគ្រោះថ្នាក់ | បណ្តាលឱ្យពុលប្រសិនបើលេបចូល | H301 |
| | | Dermal | | | | បណ្តាលឱ្យពុលប្រសិនបើប៉ះនឹងស្បែក | H311 |
| | | ការដកដង្ហើមចូល | | | | បណ្តាលឱ្យពុលប្រសិនបើដកដង្ហើមចូល | H331 |
| | 4 | ផ្ទាល់មាត់ |  | មិនត្រូវការ | សញ្ញាព្រមាន | បណ្តាលឱ្យគ្រោះថ្នាក់ប្រសិនបើលេបចូល | H302 |
| | | Dermal | | | | បណ្តាលឱ្យគ្រោះថ្នាក់ប្រសិនជាប៉ះជាមួយស្បែក | H312 |
| | | ការដកដង្ហើមចូល | | | | បណ្តាលឱ្យគ្រោះថ្នាក់ប្រសិនបើដកដង្ហើមចូល | H332 |
| | 5 | ផ្ទាល់មាត់ | គ្មានរូបសញ្ញា | មិនត្រូវការ | សញ្ញាព្រមាន | អាចបណ្តាលឱ្យមានគ្រោះថ្នាក់ប្រសិនបើលេបចូល | H303 |
| | | Dermal | | | | អាចបណ្តាលឱ្យមានគ្រោះថ្នាក់ប្រសិនបើប៉ះជាមួយស្បែក | H313 |
| | | ការដកដង្ហើមចូល | | | | អាចបណ្តាលឱ្យគ្រោះថ្នាក់ប្រសិនបើដកដង្ហើមចូល | H333 |

## ២.២. រលាកស្បែក

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | លេខកូដបង្គ្រោះថ្នាក់ |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គ្រោះថ្នាក់ | ក្រុមបង្គ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ GHS | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ UN Model Regulations | ពាក្យព្រមាន | ភាពអាចបង្គ្រោះថ្នាក់ | |
| ប្រតិកម្មស្បែករមាស់ | 1 |  |  | សញ្ញាបង្គ្រោះថ្នាក់ | បណ្តាលឱ្យរលាកស្បែកនិងភ្នែកធ្ងន់ធ្ងរ | H314 |
| | 2 |  | មិនត្រូវការ | សញ្ញាព្រមាន | បណ្តាលឱ្យរមាស់ស្បែក | H315 |
| | 3[a] | គ្មានរូបសញ្ញា | មិនត្រូវការ | សញ្ញាព្រមាន | បណ្តាលឱ្យរមាស់ស្បែកតិចតួច | H316 |

## ២.៣. រលាកភ្នែកធ្ងន់ធ្ងរ

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | លេខកូដបង្គ្រោះថ្នាក់ |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គ្រោះថ្នាក់ | ក្រុមបង្គ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ GHS | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ UN Model Regulations | ពាក្យព្រមាន | ភាពអាចបង្គ្រោះថ្នាក់ | |
| រលាកភ្នែកធ្ងន់ធ្ងរ | 1 |  | មិនត្រូវការ | សញ្ញាបង្គ្រោះថ្នាក់ | បណ្តាលឱ្យខូចភ្នែកធ្ងន់ធ្ងរ | H318 |
| | 2/2A |  | មិនត្រូវការ | សញ្ញាព្រមាន | បណ្តាលឱ្យប៉ះពាល់ភ្នែកធ្ងន់ធ្ងរ | H319 |

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | លេខកូដបង្គ្រោះថ្នាក់ |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គ្រោះថ្នាក់ | ក្រុមបង្គ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ | | ពាក្យព្រមាន | ភាពអាចបង្គ្រោះថ្នាក់ | |
| | | GHS | UN Model Regulations | | | |
| | 2B | គ្មានរូបសញ្ញា | មិនត្រូវការ | សញ្ញាព្រមាន | បណ្ដាលឱ្យប៉ះពាល់ភ្នែក | H320 |

## ២.៤_ មានជំងឺប្រតិកម្ម ឬប្រតិកម្មដំណកដង្ហើម

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | លេខកូដបង្គ្រោះថ្នាក់ |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គ្រោះថ្នាក់ | ក្រុមបង្គ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ | | ពាក្យព្រមាន | ភាពអាចបង្គ្រោះថ្នាក់ | |
| | | GHS | UN Model Regulations | | | |
| មានជំងឺប្រតិកម្ម ឬប្រតិកម្មដំណកដង្ហើម | 1 |  | មិនត្រូវការ | សញ្ញាបង្គ្រោះថ្នាក់ | អាចបណ្ដាលឱ្យមានប្រតិកម្មឬរោគសញ្ញាហឺត ឬពិបាកដកដង្ហើមប្រសិនបើដកដង្ហើមចូល | H334 |
| | 1A[a] |  | មិនត្រូវការ | សញ្ញាបង្គ្រោះថ្នាក់ | អាចបណ្ដាលឱ្យមានប្រតិកម្មឬរោគសញ្ញាហឺត ឬពិបាកដកដង្ហើមប្រសិនបើដកដង្ហើមចូល | H334 |
| | 1B[a] |  | មិនត្រូវការ | សញ្ញាបង្គ្រោះថ្នាក់ | អាចបណ្ដាលឱ្យមានប្រតិកម្មឬរោគសញ្ញាហឺត ឬពិបាកដកដង្ហើមប្រសិនបើដកដង្ហើមចូល | H334 |

## ២.៥. មានជំងឺប្រតិកម្ម ឬប្រតិកម្មស្បែក

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | លេខកូដបង្គ្រោះថ្នាក់ |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គ្រោះថ្នាក់ | ក្រុមបង្គ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ GHS | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ UN Model Regulations | ពាក្យព្រមាន | ភាពអាចបង្គ្រោះថ្នាក់ | |
| មានប្រតិកម្មឬប្រតិកម្មស្បែក | 1 |  | មិនត្រូវការ | សញ្ញាព្រមាន | អាចបណ្ដាលឱ្យមានប្រតិកម្មលោកស្បែក | H317 |
| | 1A[a] |  | មិនត្រូវការ | សញ្ញាព្រមាន | អាចបណ្ដាលឱ្យមានប្រតិកម្មលោកស្បែក | H317 |
| | 1B[a] |  | មិនត្រូវការ | សញ្ញាព្រមាន | អាចបណ្ដាលឱ្យមានប្រតិកម្មលោកស្បែក | H317 |

## ២.៦. ធ្វើឱ្យខូចកោសិកា

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | លេខកូដបង្គ្រោះថ្នាក់ |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គ្រោះថ្នាក់ | ក្រុមបង្គ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ GHS | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ UN Model Regulations | ពាក្យព្រមាន | ភាពអាចបង្គ្រោះថ្នាក់ | |
| ធ្វើឱ្យខូចកោសិកា | 1 (ទាំង 1A និង1B) |  | មិនត្រូវការ | សញ្ញាបង្គ្រោះថ្នាក់ | អាចបណ្ដាលឱ្យខូចហ្សេនទិក | H340 |

| | | | | | | |
|---|---|---|---|---|---|---|
| | 2 |  | មិនត្រូវការ | សញ្ញាបង្ក គ្រោះថ្នាក់ | ត្រូវបានសង្ស័យថាខូចហ្សែនទិក | H341 |

## ២.៧. កើតមហារីក

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | លេខកូដ បង្កគ្រោះថ្នាក់ |
|---|---|---|---|---|---|---|
| | | រូបសញ្ញានៃភាពបង្កគ្រោះថ្នាក់ | | | | |
| ចំណាត់ថ្នាក់ បង្កគ្រោះថ្នាក់ | ក្រុមបង្កគ្រោះថ្នាក់ | GHS | UN Model Regulations | ពាក្យព្រមាន | ភាពអាចបង្កគ្រោះថ្នាក់ | |
| កើតមហារីក | 1<br>( ទាំង1Aនិង1B) |  | មិនត្រូវការ | សញ្ញាបង្ក គ្រោះថ្នាក់ | អាចបណ្ដាលឱ្យកើតមហារីក | H350 |
| | 2 |  | មិនត្រូវការ | សញ្ញាបង្ក គ្រោះថ្នាក់ | ត្រូវបានសង្ស័យថាបណ្ដាលឱ្យកើតមហារីក | H351 |

## ២.៨. មានគ្រោះថ្នាក់ដល់ការបង្កកំណើតទារកនិងកុមារ

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | លេខកូដ បង្កគ្រោះថ្នាក់ |
|---|---|---|---|---|---|---|
| | | រូបសញ្ញានៃភាពបង្កគ្រោះថ្នាក់ | | | | |
| ចំណាត់ថ្នាក់ បង្កគ្រោះថ្នាក់ | ក្រុមបង្កគ្រោះថ្នាក់ | GHS | UN Model Regulations | ពាក្យព្រមាន | ភាពអាចបង្កគ្រោះថ្នាក់ | |
| បង្កគ្រោះថ្នាក់ ដល់ការបង្ក កំណើត | 1<br>( ទាំង 1A និង 1B) |  | មិនត្រូវការ | សញ្ញាបង្ក គ្រោះថ្នាក់ | អាចបណ្ដាលឱ្យប៉ះពាល់ដល់ការបង្កកំណើត ឬទារកមិនទាន់កើត | H370 |

| | | | | | | |
|---|---|---|---|---|---|---|
| | 2 |  | មិនត្រូវការ | សញ្ញាព្រមាន | ត្រូវបានគេសង្ស័យថាប៉ះពាល់ដល់ការបង្កកំណើត ឬទារកមិនទាន់កើត | H371 |
| | ក្រុមដទៃទៀតដែលប៉ះពាល់ ឬតាមរយៈការបំបៅ | គ្មានរូបសញ្ញា | មិនត្រូវការ | គ្មានសញ្ញាព្រមាន | អាចបណ្តាលឱ្យប៉ះពាល់ដល់ ការបំបៅកូនដោយទឹកដោះដល់ទារក | H335<br>H336 |

## ២.៩_ បំពុលសរីរាង្គជាក់លាក់មួយ ពេលទទួលរងសារធាតុគីមីមួយដង

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | លេខកូដបង្គ្រោះថ្នាក់ |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គ្រោះថ្នាក់ | ក្រុមបង្គ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ | | ពាក្យព្រមាន | ភាពអាចបង្គ្រោះថ្នាក់ | |
| | | GHS | UN Model Regulations | | | |
| បំពុលសរីរាង្គជាក់លាក់មួយ ពេលទទួលរងសារធាតុគីមីមួយដង | 1 |  | មិនត្រូវការ | សញ្ញាបង្គ្រោះថ្នាក់ | អាចបណ្តាលឱ្យប៉ះពាល់ដល់សរីរាង្គគោលដៅ | H370 |
| | 2 |  | មិនត្រូវការ | សញ្ញាព្រមាន | អាចបណ្តាលឱ្យប៉ះពាល់ដល់សរីរាង្គគោលដៅ | H371 |
| | 3 |  | មិនត្រូវការ | សញ្ញាព្រមាន | អាចបណ្តាលឱ្យរលាកប្រព័ន្ធដំណកដង្ហើម ឬអាចបណ្តាលឱ្យវិលមុខ | H335<br>H336 |

## ២.១០. បំពុលសរីរាង្គជាក់លាក់មួយពេលទទួលរងសារធាតុគីមីច្រើនដង

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | លេខកូដបង្គ្រោះថ្នាក់ |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គ្រោះថ្នាក់ | ក្រុមបង្គ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ GHS | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ UN Model Regulations | ពាក្យព្រមាន | ភាពអាចបង្គ្រោះថ្នាក់ | |
| បំពុលសរីរាង្គជាក់លាក់មួយពេលទទួលរងសារធាតុគីមីច្រើនដង | 1 |  | មិនត្រូវការ | សញ្ញាបង្គ្រោះថ្នាក់ | បណ្ដាលឱ្យប៉ះពាល់ដល់សរីរាង្គគេទ | H372 |
| | 2 |  | មិនត្រូវការ | សញ្ញាព្រមាន | បណ្ដាលឱ្យប៉ះពាល់ដល់សរីរាង្គគេទ | H373 |

## ២.១១. ធ្វើឱ្យខូចប្រព័ន្ធផ្លូវដង្ហើម

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | លេខកូដបង្គ្រោះថ្នាក់ |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គ្រោះថ្នាក់ | ក្រុមបង្គ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ GHS | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ UN Model Regulations | ពាក្យព្រមាន | ភាពអាចបង្គ្រោះថ្នាក់ | |
| ធ្វើឱ្យខូចប្រព័ន្ធផ្លូវដង្ហើម | 1 |  | មិនត្រូវការ | សញ្ញាបង្គ្រោះថ្នាក់ | អាចបណ្ដាលឱ្យស្លាប់ប្រសិនបើលេបចូល និងតាមប្រព័ន្ធខ្យល់ | H304 |
| | 2 |  | មិនត្រូវការ | សញ្ញាព្រមាន | អាចបង្គ្រោះថ្នាក់ប្រសិនបើលេបចូល និងតាមប្រព័ន្ធខ្យល់ | H305 |

## ៣. ក្រុមសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ដែលអាចបង្កគ្រោះថ្នាក់ដល់ជីវិតក្នុងបរិស្ថានទឹក

### ៣.១. បង្កគ្រោះថ្នាក់ដល់ជីវិតក្នុងបរិស្ថានទឹករយៈពេលខ្លី

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | លេខកូដបង្កគ្រោះថ្នាក់ |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្កគ្រោះថ្នាក់ | ក្រុមបង្កគ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្កគ្រោះថ្នាក់ GHS | រូបសញ្ញានៃភាពបង្កគ្រោះថ្នាក់ UN Model Regulations | ពាក្យព្រមាន | ភាពអាចបង្កគ្រោះថ្នាក់ | |
| បង្កគ្រោះថ្នាក់ដល់ជីវិតក្នុងបរិស្ថានទឹក | ធ្ងន់ធ្ងរកម្រិត១ |  |  | សញ្ញាព្រមាន | ពុលខ្លាំងដល់ជីវិតក្នុងបរិស្ថានទឹក | H400 |
| | ធ្ងន់ធ្ងរកម្រិត២ | គ្មានរូបសញ្ញា | មិនត្រូវការ | គ្មានសញ្ញាព្រមាន | ពុលដល់ជីវិតក្នុងបរិស្ថានទឹក | H401 |
| | ធ្ងន់ធ្ងរកម្រិត៣ | គ្មានរូបសញ្ញា | មិនត្រូវការ | គ្មានសញ្ញាព្រមាន | បង្កគ្រោះថ្នាក់ដល់ជីវិតក្នុងបរិស្ថានទឹក | H402 |

### ៣.២. បង្កគ្រោះថ្នាក់ដល់ជីវិតក្នុងបរិស្ថានទឹករយៈពេលវែង

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | លេខកូដបង្កគ្រោះថ្នាក់ |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្កគ្រោះថ្នាក់ | ក្រុមបង្កគ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្កគ្រោះថ្នាក់ GHS | រូបសញ្ញានៃភាពបង្កគ្រោះថ្នាក់ UN Model Regulations | ពាក្យព្រមាន | ភាពអាចបង្កគ្រោះថ្នាក់ | |
| បង្កគ្រោះថ្នាក់ដល់ជីវិតក្នុងបរិស្ថានទឹករយៈពេលវែង | ពុលរ៉ាំរ៉ៃកម្រិត១ |  |  | សញ្ញាព្រមាន | ពុលខ្លាំងដល់ជីវិតក្នុងបរិស្ថានទឹករយៈពេលវែង | H410 |
| | ពុលរ៉ាំរ៉ៃកម្រិត២ |  |  | គ្មានសញ្ញាព្រមាន | ពុលដល់ជីវិតក្នុងបរិស្ថានទឹករយៈពេលវែង | H411 |
| | ពុលរ៉ាំរ៉ៃកម្រិត៣ | គ្មានរូបសញ្ញា | មិនត្រូវការ | គ្មានសញ្ញាព្រមាន | បង្កគ្រោះថ្នាក់ដល់ជីវិត | H412 |

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គ្រោះថ្នាក់ | ក្រុមបង្គ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ GHS | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ UN Model Regulations | ពាក្យព្រមាន | ភាពអាចបង្គ្រោះថ្នាក់ | លេខកូដបង្គ្រោះថ្នាក់ |
| | | | | | ក្នុងបរិស្ថានទឹករយៈពេលវែង | |
| | ពុលរ៉ាំរ៉ៃកម្រិត៤ | គ្មានរូបសញ្ញា | មិនត្រូវការ | គ្មានសញ្ញាព្រមាន | អាចបណ្តាលឱ្យគ្រោះថ្នាក់ដល់ជីវិតក្នុងបរិស្ថានទឹករយៈវែង | H413 |

## ៤. ក្រុមសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់ដែលអាចបង្គ្រោះថ្នាក់ដល់ស្រទាប់អូហ្សូន

### ៤.១. បង្គ្រោះថ្នាក់ដល់ស្រទាប់អូហ្សូន

| ការចាត់ថ្នាក់ | | ការដាក់ស្លាកសញ្ញា | | | | |
|---|---|---|---|---|---|---|
| ចំណាត់ថ្នាក់បង្គ្រោះថ្នាក់ | ក្រុមបង្គ្រោះថ្នាក់ | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ GHS | រូបសញ្ញានៃភាពបង្គ្រោះថ្នាក់ UN Model Regulations | ពាក្យព្រមាន | ភាពអាចបង្គ្រោះថ្នាក់ | លេខកូដបង្គ្រោះថ្នាក់ |
| បង្គ្រោះថ្នាក់ដល់ស្រទាប់អូហ្សូន | 1 |  | មិនត្រូវការ | សញ្ញាព្រមាន | បង្គ្រោះថ្នាក់ដល់សុខភាពសាធារណៈនិងបរិស្ថានដោយការបំផ្លាញស្រទាប់អូហ្សូនខាងលើ | H420 |

**ឧបសម្ព័ន្ធ៣ នៃអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០២១**

**ស្ដីពី**

**ការកែសម្រួលមាត្រា៧ មាត្រា១២ មាត្រា១៣ មាត្រា១៤ ឧបសម្ព័ន្ធ២ ឧបសម្ព័ន្ធ៣ និង ឧបសម្ព័ន្ធ៤ នៃអនុក្រឹត្យលេខ១៨០ អនក្រ.បក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ ស្ដីពីការគ្រប់គ្រងលើការចាត់ថ្នាក់និងការដាក់ស្លាកសញ្ញាសារធាតុគីមី**

| | | |
|---|---|---|
| <br>សញ្ញាបង្កការផ្ទុះ<br>(លេខកូដ : GHS01) | <br>សញ្ញាគ្រោះថ្នាក់ដោយភ្លើង<br>(លេខកូដ : GHS02) | <br>សញ្ញាគ្រោះថ្នាក់ដោយឧស្ម័ន<br>(លេខកូដ : GHS03) |
| <br>សញ្ញាបំពង់ដាក់ឧស្ម័នបណ្ណែន<br>(លេខកូដ : GHS04) | <br>សញ្ញាបង្កការរលាកឬច្រេះស៊ី<br>(លេខកូដ : GHS05) | <br>សញ្ញាបង្កគ្រោះថ្នាក់ដល់ស្លាប់<br>(លេខកូដ : GHS06) |
| <br>សញ្ញាឱ្យប្រុងប្រយ័ត្ន<br>(លេខកូដ : GHS07) | <br>សញ្ញាបង្កគ្រោះថ្នាក់ដល់មនុស្ស<br>(លេខកូដ : GHS08) | <br>សញ្ញាបង្កគ្រោះថ្នាក់ដល់បរិស្ថាន<br>(លេខកូដ : GHS09) |

# ឧបសម្ព័ន្ធ៤ នៃអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០២១
# ស្តីពី
# ការកែសម្រួលមាត្រា៧ មាត្រា១២ មាត្រា១៣ មាត្រា១៤ ឧបសម្ព័ន្ធ២ ឧបសម្ព័ន្ធ៣ និង ឧបសម្ព័ន្ធ៤ នៃអនុក្រឹត្យលេខ១៨០ អនក្រ.បក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងលើការចាត់ថ្នាក់និងការដាក់ស្លាកសញ្ញាសារធាតុគីមី

## ទម្រង់គោលនៃឯកសារព័ត៌មានអំពីសុវត្ថិភាពសម្រាប់សារធាតុគីមីនិងផលិតផលគីមី

| ល.រ. | ចំណុចសំខាន់ៗ | ការបរិយាយក្នុងឯកសារព័ត៌មានអំពីសុវត្ថិភាព (SDS) |
|---|---|---|
| ១ | ព័ត៌មានអំពី ផលិតផល និង អ្នកផ្គត់ផ្គង់ | (ក) ព័ត៌មានផលិតផល<br>(ខ) ព័ត៌មានផ្សេងៗទៀត<br>(គ) ព័ត៌មានស្តីពីការប្រើប្រាស់សារធាតុគីមីនិងលក្ខខណ្ឌប្រើប្រាស់<br>(ឃ) ព័ត៌មានលម្អិតអំពីអ្នកផ្គត់ផ្គង់(ឈ្មោះ អាសយដ្ឋាន លេខទូរសព្ទ ល។)<br>(ង) លេខទូរសព្ទបន្ទាន់ |
| ២ | ព័ត៌មានអំពី ភាពអាចបង្កគ្រោះថ្នាក់ | (ក) ចំណាត់ថ្នាក់ GHS នៃសារធាតុនិងព័ត៌មានជាតិឬតំបន់<br>(ខ) ការដាក់ស្លាកសញ្ញា GHS រួមមានព័ត៌មានអំពីវិធានការបង្ការ (រូបសញ្ញានៃភាពអាចបង្កគ្រោះថ្នាក់ត្រូវបានបង្កើតជាថ្មីដែលមានពណ៌ខ្មៅ ឬស ឬឈ្មោះនៃរូបសញ្ញាដូចជា "សញ្ញាឆាបឆេះ" "សញ្ញាបង្កគ្រោះថ្នាក់ដល់ស្លាប់"<br>(គ) ភាពអាចបង្កគ្រោះថ្នាក់ផ្សេងៗទៀតដែលមិនមានក្នុងការចាត់ថ្នាក់ឬមិនមានក្នុង GHS |
| ៣ | ព័ត៌មានអំពី ធាតុបន្សំនៃផលិតផល | <u>សារធាតុ</u><br>(ក) ព័ត៌មានសារធាតុគីមី<br>(ខ) ឈ្មោះទូទៅ ឈ្មោះស្រដៀងគ្នា<br>(គ) CAS Number និងព័ត៌មានផ្សេងៗទៀត<br>(ឃ) ការចាត់ថ្នាក់សារធាតុបន្ថែមដែលមិនសុទ្ធ សារធាតុមានលំនឹង និងសារធាតុគីមីផ្សេងៗទៀត<br><u>ល្បាយ</u><br>ព័ត៌មានសារធាតុគីមីនិងកំហាប់ដែលបង្កគ្រោះថ្នាក់ |
| ៤ | វិធានការ សង្គ្រោះបឋម | (ក) ចំពោះការពិពណ៌នាពីវិធានការចាំបាច់ត្រូវបានធ្វើការបែងចែកដោយយោងតាមលំនាំនៃផលប៉ះពាល់ផ្សេងៗគ្នាដូចជា ការដកដង្ហើមចូល ការប៉ះដោយផ្ទាល់ដោយស្បែក និងភ្នែក និងការលេបចូល<br>(ខ) រោគសញ្ញាឬផលប៉ះពាល់<br>(គ) ការបង្ហាញនូវអាការៈភ្លាមៗនិងតម្រូវការព្យាបាលប្រសិនជាចាំបាច់ |
| ៥ | វិធានការ បង្ការអគ្គិភ័យ | (ក) ប្រព័ន្ធពន្លត់អគ្គីភ័យដែលសមស្រប និងមិនសមស្រប (ខ) គ្រោះបង្កគ្រោះថ្នាក់ជាក់លាក់ដែលកើតចេញពីសារធាតុគីមី(ធម្មជាតិនៃផលិតផលចំហេះ ដែលជាគ្រោះថ្នាក់)<br>(គ) ឧបករណ៍ការពារអគ្គិភ័យ |

| ល.រ. | ចំណុចសំខាន់ៗ | ការបរិយាយក្នុងឯកសារព័ត៌មានអំពីសុវត្ថិភាព (SDS) |
|---|---|---|
| ៦ | វិធានការ<br>បង្ការសាយភាយ | (ក) ឧបករណ៍ការពារខ្លួននិងដំណើរសង្គ្រោះបន្ទាន់<br>(ខ) ការការពារបរិស្ថាន<br>(គ) វិធីសាស្ត្រនិងសម្ភារៈសម្រាប់គ្រប់គ្រងលើហានិភ័យ និង |
| ៧ | ការប្រើប្រាស់និងស្តុក | (ក) វិធានការសម្រាប់ការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព<br>(ខ) លក្ខខណ្ឌសម្រាប់ការស្តុកទុកប្រកបដោយសុវត្ថិភាព |
| ៨ | ការការពារ<br>សុវត្ថិភាពកម្មករ | (ក) ប៉ារ៉ាម៉ែត្រ (e.g occupational exposure limit values or biological limit values)<br>(ខ) ការគ្រប់គ្រងបែបវិស្វកម្មសមស្រប<br>(គ) វិធានការការពារសម្រាប់បុគ្គលនីមួយៗដូចជាឧបករណ៍ការពារសុវត្ថិភាពផ្ទាល់ខ្លួន |
| ៩ | លក្ខណរូប និង<br>លក្ខណៈគីមីផលិតផល | ភាពរូប ពណ៌ ក្លិន ចំណុចរលាយ / ចំណុចកំណក ចំណុចរំពុះ ភាពងាយឆាបឆេះ កម្រិតបន្ទុះ ចំណុចផ្ទាត សីតុណ្ហភាពឆាបឆេះដោយឯកឯង សីតុណ្ហភាពបំបែកជាតុ pH (ប៉ូតង់ស្យែលអ៊ីដ្រូសែន) ល្បឿនប្រតិកម្មស៊ីនេទិច(Kinetic viscosity) ភាពដែលអាចរលាយ ដង់ស៊ីតេ ដង់ស៊ីតេចំណុចរំហួត លក្ខណៈភាគល្អិត |
| ១០ | លំនឹង និងប្រតិកម្ម | (ក) ប្រតិកម្ម<br>(ខ) លំនឹងគីមី<br>(គ) ភាពដែលអាចកើតឡើងនៃប្រតិកម្មគីមី<br>(ឃ) លក្ខខណ្ឌជៀសវាង (បន្ទុក, រំញ័រ)<br>(ង) សម្ភារៈដែល (incompatible)<br>(ច) ផលិតផលគ្រោះថ្នាក់ដែលអាចបំបែកជាតុ (hazardous decomposition products) |
| ១១ | ព័ត៌មានអំពី<br>តុកស៊ីកូឡូស៊ី | ច្បាស់លាស់ប៉ុន្តែជាការពិពណ៌នាអំពីព័ត៌មានតុកស៊ីកូឡូស៊ីដែលត្រឹមត្រូវ និងអាចយល់បាន (ផលប៉ះពាល់នៃសុខភាព និងទិន្នន័យដែលមានស្រាប់ត្រូវបានប្រើដើម្បីកំណត់អំពីផលប៉ះពាល់រួមមាន៖<br>(ក) ព័ត៌មានស្តីអំពីលំនាំនៃផលប៉ះពាល់ ( ការដកដង្ហើមចូល ការលេបចូល ផលប៉ះពាល់ដល់ស្បែក និងភ្នែក<br>(ខ) រោគសញ្ញាពាក់ព័ន្ធនឹងលក្ខណៈរូប គីមី និងតុកស៊ីកូឡូស៊ី<br>(គ) ផលប៉ះពាល់ (delayed) និងភ្លាមៗ និងផលប៉ះពាល់រ៉ាំរ៉ៃដែលទទួលរងក្នុងរយៈពេលខ្លី និងវែង<br>(ឃ) វិធានការនៃតុកស៊ីកូឡូស៊ី (ដូចជាការប៉ាន់ប្រមាណតុកស៊ីកូឡូស៊ីដែលធ្ងន់ធ្ងរ) |
| ១២ | ព័ត៌មានអំពី<br>ឥទ្ធិពលទៅលើ<br>អេកូឡូស៊ី | (ក) ភាពពុល (មជ្ឈដ្ឋានទឹកនិងមជ្ឈដ្ឋានដីប្រសិនបើមាន)<br>(ខ) មិនងាយបំបែកជាតុ (persistence) និង ខូចគុណភាព (degradability)<br>(គ) សក្តានុពលនៃកំណើនបរិមាណតាមបែបជីវៈ (bioaccumulative)<br>(ឃ) បម្លាស់ទីក្នុងដី (mobility in soil)<br>(ង) ផលប៉ះពាល់ផ្សេងៗទៀត |
| ១៣ | ការគិតគូរពី<br>ការបោះបង់ចោល | ការពិពណ៌នាអំពីសំណល់ និងព័ត៌មានពីការប្រើប្រាស់ និងវិធីសាស្ត្របោះបង់រួមមានការបោះបង់នូវសម្ភារៈវេចខ្ចប់ដែលកង្វក់ |
| ១៤ | ព័ត៌មានអំពី | (ក) លេខរបស់ UN |

| ល.រ. | ចំណុចសំខាន់ៗ | ការបរិយាយក្នុងឯកសារព័ត៌មានអំពីសុវត្ថិភាព (SDS) |
|---|---|---|
| | សុវត្ថិភាពដឹកជញ្ជូន | (ខ) ឈ្មោះដឹកជញ្ជូនរបស់ UN ដែលសមស្រប<br>(គ) ចំណាត់ថ្នាក់បង្កគ្រោះថ្នាក់ពេលដឹកជញ្ជូន<br>(ឃ) ក្រុមវេចខ្ចប់ប្រសិនបើមាន<br>(ង) គ្រោះថ្នាក់ដល់បរិស្ថាន ( សារធាតុបំពុលសមុទ្រ (មាន/ មិនមាន )<br>(ច) ការដឹកជញ្ជូនក្នុងបរិមាណច្រើន<br>(ជ) វិធានការបង្ការពិសេសដែលអ្នកប្រើប្រាស់ត្រូវដឹង ឬត្រូវការដោយអនុលោមតាមការដឹកជញ្ជូន ឬការដឹកជញ្ជូនទាំងក្នុង ឬក្រៅបរិវេណ |
| ១៥ | ព័ត៌មានអំពីបញ្ញត្តិច្បាប់គ្រួតពិនិត្យ | លិខិតបទដ្ឋានស្ដីពីសុវត្ថិភាព សុខភាព បរិស្ថានរបស់ផលិតផល |
| ១៦ | ព័ត៌មានផ្សេងៗ | |